ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខ:........................

ថ្ងៃ................ខែ............ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី.......ខែ..........ឆ្នាំ២០១៩

## សេចក្តីជូនដំណឹងលើកទី២
## ស្តីពី
## ការអញ្ជើញចូលរួមពិគ្រោះថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីផ្តល់សេវាគាំទ្របរិក្ខារ SERVER និងផ្គត់ផ្គង់គ្រឿងបន្លាស់។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០រសៀល) ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ ត្រឹមវេលាម៉ោង ១៦:០០រសៀល ក្នុងមួយច្បាប់ តម្លៃ ១៦០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើពិគ្រោះថ្លៃគឺ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង ១៤:៥០នាទី នៅអគារអង្គភាពលទ្ធកម្ម (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យពិគ្រោះថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការពិគ្រោះថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារពិគ្រោះថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

ជ. គណៈកម្មាធិការលទ្ធកម្ម
អនុប្រធានទី១

បណ្ឌិត.ជា វិសុទ្ធ

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ